## អេម៉ាន្វូអែល

សំលេងពីព្រះសហគមន៍កាតូលិក

*FM: 91 Mhz ខេត្តបាត់ដំបង*

*៧:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍*

*FM: 88 Mhz ខេត្តកំពង់ធំ*

*១២:៣០- ១:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍*

*FM: 102.5 Mhz ខេត្តសៀមរាប*

*១០:០០-១១:០០ នាទី រៀងរាល់ថ្ងៃសៅរ៍*

## ការិយាល័យផ្សព្វផ្សាយព័ត៌មាន ព្រះសហគមន៍ កាតូលិក រតនះ

- បំលែងឯកសារពី VHS ទៅ DVD ទៅ VCD
- បំលែងចំរៀងពី កាសែតចម្រៀង ទៅ CD
- បង្កើតឯកសារវីឌីអូ សំរាប់ លោកឪពុក បងស្រី បងប្រុស។

ទំនាក់ទំនង ០៩២ ៦០៩ ៨៤៨

## ព័ត៌មានប្រចាំខែ ភូមិភាគ បាត់ដំបង

- ថ្ងៃទី០៩-១៣ តុលា: ពិធីសូត្រវេន នៅព្រះសហគមន៍ ព្រៃកស្បូវ ធ្វើឡើងក្នុងគោលបំណង រំលឹកវិញ្ញាណក្ខន្ធអ្នក ដែលបានស្លាប់ ក្នុងរយៈពេលប្រាំថ្ងៃ ដែលមានលោកឪពុក បងស្រី គណៈកម្មាការណ៍ និងប្អូនជាគ្រីស្តបរិស័ទដែលបានចូលរួម។
- ថ្ងៃទី១៤ តុលា: ពិធីបុណ្យភ្ជុំ ដែលមានបងប្អូនគ្រីស្តបរិស័ទ ចូលរួមយ៉ាងច្រើនកុះករ នៅព្រះសហគមន៍ សៀមរាប។
- ថ្ងៃទី២៣ តុលា: ការប្រជុំប៉ាស្ទ័រាល ក្នុងគោលបំណងវាយតម្លៃការងារ នៅព្រះសហគមន៍ សៀមរាប។
- ថ្ងៃទី០៩-១៣ តុលា: នៅព្រះសហគមន៍ កំពង់ធំ មានពីធីសូត្រវេន និងកាន់វេនរយៈពេលប្រាំថ្ងៃ។

## ល្បែងកំសាន្ត

សូមស្វែងរកចំនុចដែរខុសគ្នាចំនួន៩ចំនុច





Apostolic Prefecture of Battambang Monthly News. For Internal Circulation

# រតនះ

មហាគ្រួសារព្រះសហគមន៍ កាតូលិក

Our Family

ព័ត៌មានព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង ប្រចាំខែ តុលា ឆ្នាំ ២០១២ លេខ ៥៤




# សិក្ខាសាលាព្រះគម្ពីរជាមូលដ្ឋាន

## មាតិកា








- ពិធីគោរពព្រះបរមសព និងព្រះវិញ្ញាណក្ខន្ធ ព្រះមហាវិរក្សត្រ ទំព័រ ២
- ការប្រកួតកីឡាតេក្វាន់ដូ ជ្រើសរើសជើងឯក ទំព័រ ៦
- អបអរសាទរពិធីបុណ្យភ្ជុំ ទំព័រ ៤-៥

ទំព័រ ៣

# ពិធីគោរពព្រះបរមសព និងព្រះវិញ្ញាណក្ខន្ធ ព្រះមហាវិរក្សត្រ ព្រះករុណា ព្រះបាទនរោត្តម សីហនុ



Photo: An Rittyrath

ដោយៈមុយ សាម៉េត

**ក្នុងរយៈពេលប្រាំពីរថ្ងៃនៃការកាន់ទុក្ខ គ្រប់ប្រជារាស្ត្រទូទាំងប្រទេសមានការកើតទុក្ខជាខ្លាំង នឹងមានចិត្តយ៉ាងក្រៀមក្រំ និងអាលោះអាល័យជាប៉ុនពេក ចំពោះព្រះមហាវិរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ដែលទ្រង់បានសោយព្រះទីវង្គត់ទៅ។**

កាលពីថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ព្រះសហគមន៍ កាតូលិកបាត់ដំបង បានចូលរួមធ្វើការគោរពព្រះសព និងព្រះវិញ្ញាណក្ខន្ធ ព្រះមហាវិរក្សត្រ នៅព្រះវិហារ សេចក្តីមេត្តាករុណានៃព្រះគ្រីស្ត ខេត្តបាត់ដំបង។ ពិធីគោរពព្រះបរមសព និងព្រះវិញ្ញាណក្ខន្ធ របស់ព្រះមហាវិរក្សត្រ បានប្រារព្ធឡើងក្នុងគោលបំណង គឺចង់បង្ហាញជាតិសាសនាតែមួយ ព្រះមហាក្សត្រតែមួយ និងជាប្រជារាស្ត្រនៃជនជាតិខ្មែរតែមួយដើម្បីប្រួបរួមគ្នា នូវការដឹងគុណដ៏ធំធេងចំពោះព្រះមហាវិរក្សត្រ ព្រះបាទព្រះនរោត្តម សីហនុ។ នៅក្នុងនោះក៏មានការចូលរួមពីតំណាង មន្ទីរធម្មការណ៍ សមាគមន៍គ្រីស្តស្ទាន ព្រះសហគមន៍ កាតូលិកបាត់ដំបង ព្រមទាំងអង្គការនានា ប្រមាណជា ៥០០នាក់។ ក្នុងនោះលោក ទេព បញ្ញា ជាគ្រូគង្វាលខាងសាសនាគ្រីស្តស្ទាន ក៏បានប្រកាសហេតុអំពីពិធីព្រះបរមសព ដែលថា "នេះជាថ្ងៃចុងក្រោយនៃការកាន់ទុក្ខ ដែលមានរយៈពេលប្រាំពីរថ្ងៃ ហើយក្នុងថ្ងៃនេះជាថ្ងៃពរពេញដោយសេចក្តីទុក្ខ ដោយព្រះបាទព្រះនរោត្តម សីហនុ បានចូលយាងទីវង្គត់នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង០១:២០ នាទីយប់ នៅមន្ទីរពេទ្យទីក្រុងប៉េកាំង ប្រទេសចិន"។ បន្ទាប់ពីការប្រកាសហេតុពិធីព្រះបរមសពរួចមក ក្នុងនោះលោក គឹម សារ៉ាវុធ និងអ្នកនាង គយ កាញ្ចនា ជាគ្រូគង្វាលសាសនាគ្រីស្តស្ទាន បានអាននូវជីវៈប្រវត្តិសង្ខេប របស់ព្រះករុណា ព្រះបាទនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គប្រសូតនៅថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំច ចត្វាស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ នៅរាជធានីភ្នំពេញ។ ពីឆ្នាំ១៩៣០ ដល់១៩៥០ព្រះអង្គបានចូលសិក្សានៅ សាលាបឋមសិក្សា Francois Baudoin និងវិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ វិទ្យាល័យបារាណសាសឡូនបា (ycee chasseloup Laubat ) នៅព្រៃនគរ(វៀតណាមខាងត្បូង)។ ព្រះអង្គបានគ្រងរាជ្យសម្បត្តិនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៥១។ បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យពីប្រទេសបារាំង ព្រះអង្គបានដាក់រាជ្យថ្វាយព្រះបិតា នៅថ្ងៃទី០២ ខែមិនា ឆ្នាំ១៩៥៥។ បន្ទាប់មកទៀតព្រះអង្គបានឡើងគ្រងរាជ្យលើកទី២ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយទ្រង់ក៏ដាក់រាជ្យវិញនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥។ ក្រោយពីការដាក់រាជ្យ ព្រះអង្គត្រូវបានគេថ្វាយព្រះកិត្តិតនាមថា ព្រះមហាវិរក្សត្រ។ នៅក្នុងពិធីចុងក្រោយ នៃព្រះរាជពិធីគោរពព្រះបរមសព និងគោរពព្រះវិញ្ញាក្ខន្ធ គ្រប់សាសនានិកាយទាំងអស់ ព្រមទាំងស្ថាប័នអង្គការនានា បានយកកំរងផ្កាមកថ្វាយ និងស្មឹងស្មាធចំពោះព្រះភគ្រ្តឆាយាលក្ខណ៍ ដោយទឹកចិត្តយ៉ាងក្រៀមក្រំ ចំពោះការសោយទីវង្គត់របស់ព្រះអង្គ។



# សន្តី ថេរេសា នៅក្រុង លីស៊ុយឺ

**ក្នុងរតនះលេខមុន យើងបានស្គាល់ សន្តី ថេរេសា នៅក្រុង លីស៊ុយឺ រីឯលេខនេះគឺ យើងបន្តអាននូវប្រវត្តិ របស់សន្តី ថេរេសា បន្តទៀត។ តើ ថេរេសា បានសរសេរអ្វីខ្លះ ដែលបញ្ជាក់ថាជាសេចក្តីស្រឡាញ់?តើ ថេរេសា បាននិយាយពាក្យសាមញ្ញយ៉ាងដូចម្តេចដែរ នៅក្នុងអត្ថបទនេះ? ដូចនេះ សូមអានក្នុងអត្ថបទខាងក្រោម នេះទាំងអស់គ្នា។**



ហេតុនាងឆ្លើយតប ទៅបងស្រីម៉ារីថាៈ ហេតុដូចម្តេចបានជាបងស្រី សួរនាងខ្ញុំថា តើបងអាចស្រឡាញ់ព្រះជាម្ចាស់ដ៏សប្បុសដូចនាងខ្ញុំបានដែរឬទេ? ប្រសិនបើបងបានយល់សេចក្តី ដែលនាងខ្ញុំធ្លាប់សរសេរ នោះបងក៏ជាសេចក្តីស្រឡាញ់ និងភាពដ៏តូចតាច និងភាពខ្វះខាតរបស់នាងខ្ញុំ។ ម្យ៉ាងទៀត គឺនាងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមាំទៅលើធម៌មេត្តាករុណា របស់ព្រះអង្គជានិច្ច។ សេចក្តីនេះ ជាកំណប់តែមួយគត់របស់នាងខ្ញុំ។ ហេតុអ្វីបានកំណប់នេះមិនអាចទៅជាកំណប់ របស់បងឯងបានដែរ? សូមអោយបងឯងយល់ច្បាស់អំពីការស្រឡាញ់ព្រះយេស៊ូ។ គឺពេលយើងខ្សោយ ពេលយើងគ្មានចង់បានអ្វី ពេលយើងគ្មានគុណសម្បត្តិ... គឺនៅពេលនោះ ព្រះហឫទ័យស្រលាញ់ របស់ព្រះអង្គអាចជំរះ និងប្រែចិត្តយើងបាន(...)។ ក្រៅពីការទុកចិត្តនឹងព្រះអង្គគ្មានអ្វី ដែលអាចធ្វើឲ្យយើងមានសេចក្តីស្រឡាញ់ទេ។ ថេរេសា បញ្ជាក់បានយ៉ាងច្បាស់ អំពីអត្ថន័យដ៏ទូលំទូលាយនៃផ្លូវដ៏តូចតាចរបស់នាងខ្ញុំ ក្នុងសំបុត្រចុងក្រោយ ដែលនាងបានផ្ញើរជូនបងស្រី លេអូនី នៅពេលបងស្រីចាកចេញពីអារាមម្តងទៀតៈ "សុភមង្គលតែមួយគត់នៅលើផែនដីនេះគឺ យើងខំប្រឹងជានិច្ចដើម្បីយល់ថាចំណែក ដែលព្រះយេស៊ូប្រទានអោយយើងជាចំណែកដ៏ល្អប្រសើ។ សូមអោយបងស្រីរស់ អំពីសេចក្តីតែមួយគត់ ដែលចាំបាច់គឺបងអាចបំពេញកិច្ចការប្រចាំថ្ងៃរបស់បងក្នុងលោកីយ៍នេះ ដោយមានគោលបំណងតែមួយគត់ គឺចង់គាប់ព្រះហឫទ័យព្រះយេស៊ូ និងរួមរស់យ៉ាងស្និតស្នាលជាមួយព្រះអង្គ"។ ប្រសិនបើមិត្តអ្នកអាន មិនទាន់យល់ច្បាស់នៅឡើយអំពីការដើរតាមផ្លូវដ៏តូចសាមញ្ញនេះ ចូរមើលពាក្យរបស់ ថេរេសា នេះ "ព្រះយេស៊ូ មិនសូមអោយនាងខ្ញុំប្រព្រឹត្តអំពើអស្ចារ្យទេ គឺព្រះអង្គសូមឲ្យនាងខ្ញុំលះបង់ខ្លួនឯង និងអរព្រះគុណព្រះអង្គ"។ "សេចក្តីស្រលាញ់ គឺផ្តល់អ្វីៗទាំងអស់ ព្រមទាំងផ្តល់ជីវិតខ្លួនឯងថែមទៀតផង"។ នៅថ្ងៃព្រហស្បតពិសិដ្ឋ ឆ្នាំ១៨៩៦ ថេរេសាឈឺ ហើយយប់ហ្នឹង...... (តលេខក្រោយ)

# ការប្រកួតកីឡាតេក្វាន់ដូ ជ្រើសរើសជើងឯក

ដោយ: មុយ សាម៉េត

**គ្រប់កីឡាទាំងអស់នៅលើពិភពលោក តែងតែមានការប្រកួតប្រជែង និងចង់បាននូវកិត្តិយស ជូនជាតិមាតុភូមិ។ នៅក្នុងនោះកីឡាតេក្វាន់ដូ ក៏មិនមើលរំលង់បានដែរ ពីព្រោះកីឡាប្រភេទនេះមានការចាប់អារម្មណ៍យ៉ាងច្រើនពីសំណាក់បងប្អូនគ្រប់មជ្ឈដ្ឋាន មិនគិតថាជាជាតិអ្វីនោះទេ។**



Photo: Moy Samet

ការប្រកួតកីឡាតេក្វាន់ដូ ជ្រើសរើសជើងឯកទូទាំងប្រទេសប្រចាំឆ្នាំ ២០១២ របស់ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការប្រកួតកាលពីថ្ងៃទី ០១-០៧ ខែ តុលា ឆ្នាំ ២០១២ នៅរាជធានីភ្នំពេញ។ ការប្រកួតរបស់ក្រសួងអប់រំនេះ មានគោលបំណង ដើម្បីស្វែងរកកីឡាករ កីឡាការិនី ដែលមានទេពកោសល្យ ផ្គួបផ្សំជាមួយ នឹងសមត្ថភាព ព្រមទាំងបច្ចេកទេសល្អៗ ក្នុងការនាំពួកគេចូលរួមក្នុងក្រុមជំរើសជាតិ។ ព្រឹត្តិការណ៍ដ៏ធំនេះ មានក្លឹបចូលរួមប្រកួត ៣៧ក្លឹប ដែលមានក្របខណ្ឌ័ផ្សេងគ្នាដូចជា WTF និង ITF ។ ហើយការប្រកួតមានពីរប្រភេទ គឺតេក្វាន់ដូ WTF និង ITF ចំនែកឯក្លឹប កាតូលិក របស់ព្រះហាគមន៍ កាតូលិកបាត់ដំបង ប្រកួតក្នុងក្របខណ្ឌ័ WTF ។ សរុបទាំងកីឡាករ កីឡាការិនី ដែលបានដាក់ពាក្យប្រកួតនៅក្នុងឆ្នាំនេះមានចំនួន ៧៣៩នាក់។ សម្រាប់ក្លឹប កាតូលិកបាត់ដំបង មានកី-ឡាករ កីឡាការិនី ចូលរួមធ្វើការប្រកួត ចំនួន ៧នាក់ ដែលប្រកួតទំនង់ខុសគ្នា និងផ្នែកខុសគ្នា រួមមានផ្នែកមេគុណបុរសនារី ព្រមទាំងផ្នែកប្រយុទ្ធបុរសជាក្រុម និងផ្នែកប្រយុទ្ធ ឯក្កាជនបុរស។ ក្នុងនោះក្រោមការដឹកនាំរបស់លោកគ្រូ ឌួង វុទ្ធី ជាលិទ្ធផលក្លឹប កាតូលិកបាត់ដំបង ដណ្តើមបានមេដាយចំនួន ៥គ្រឿង ប្រាក់១ នឹងសំរិទ្ធ៤។ កីឡាករ កីឡាការិនី ដែលបានជាប់ចំណាប់ថ្នាក់រួមមាន កីឡាការិនី លឹម គឹមហេង ប្រកួតក្នុងវិញ្ញាសារខាងផ្នែកមេគុណ ទទួលបានចំណាប់ថ្នាក់លេខ២ និងកីឡាករប្រកួតក្នុងវិញ្ញាសារក្នុងផ្នែកប្រយុទ្ធជាក្រុមរួមមាន កីឡាករ ចិត្រ ម៉ៅ កីឡាករ វិ រិទ្ធធា នឹងកីឡាករ មុយ សាម៉េត ទទួលបានចំណាប់ថ្នាក់លេខ៣ ព្រមទាំងកីឡាករ ឌួង វុទ្ធី ប្រកួតក្នុងទំនង់ធ្ងន់ទទួលបានចំណាប់ថ្នាក់លេខ៣ ផងដែរ។ ការប្រកួតកីឡាតេក្វាន់ដូទាំងពីរក្របខណ្ឌ័បានបញ្ចប់ដោយទទួលភាពជោគជ័យ និងមានការគាំទ្រពីសំណាក់បងប្អូនជាតិ និងអន្តរជាតិ។





# សិក្ខាសាលាព្រះគម្ពីរជាមូលដ្ឋាន




Photo: Moy Samet

ដោយ:មុយ សាម៉េត

កាលពីថ្ងៃទី ២៩-៣១ ខែ តុលា ឆ្នាំ ២០១២ នៅព្រះសហគមន៍ កាតូលិក បាត់ដំបង មានសិក្ខាសាលា ដែលស្តីអំពីព្រះគម្ពីរជាមូលដ្ឋាន។ សិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណងពីរ ក្នុងនោះគោលបំណងទី១ គឺចង់និយាយអំពីការបង្ហាញអោយឃើញ នូវជំនឿដ៏រឹងមាំ និងបង្កើនបទពិសោធន៍ជាមួយព្រះបន្ទូល ដែលក-សាងព្រះសហគមន៍ និងយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូល ដោយយកការអានព្រះគម្ពីរ ដើម្បីស្វែងយល់ពីជីវិតរបស់ខ្លួន។ ចំណែកគោលបំណងទី២ គឺចង់អោយពន្លកថ្មី ដែលទទួលជំហាន និងជម្រុចទឹករួច មានឱកាសបានចូលរួម ស្វែងយល់ពីសារៈប្រយោជន៍នៃព្រះគម្ពីរ និងបង្កើនបទពិសោធន៍ សម្រាប់ការយល់ដឹងអោយកាន់តែច្បាស់អំពីព្រះគម្ពីរ។ សម្រាប់សិក្ខាសាលានេះ បានរៀបចំរួចមកហើយ ដែលមានភូមិភាគកំពង់ចាម នឹងភូមិភាគភ្នំពេញ ចំនែកភូមិភាគបាត់ដំបង ក៏បានរៀបចំ នូវសិក្ខាសាលាឡើងដែរ ដោយមានការចូលរួមពីព្រះសហគមន៍ដូចជា ព្រះសហគមន៍តាហែន ស្ទឹង ទំពូង ខ្លាចរមាស និគម ស្វាយស៊ីសុផុន ប៉ោយបែត សៀមរាប តាអ៊ុំ តំបន់កំពង់ធំ និងព្រះសហគមន៍ កា-តូលិកបាត់ដំបង ជាម្ចាស់ផ្ទះ ដោយមានអ្នកចូលរួម ៩៨នាក់។ ក្នុងនោះក៏មានការចូលរួមពីសំណាក់លោកអភិបាល អាន់តូនី ដែលជាអភិបាលគ្រប់គ្រង ភូមិភាគកំពង់-ចាម លោកឪពុក បងប្រុស បងស្រី និងអ្នកសម្របសម្រួល ក្នុងសិក្ខាសាលាជាច្រើនរូបទៀតផងដែរ។ លោក កាន ប៉ុយ ដែលជាអ្នកសម្របសម្រួល នៅក្នុងកម្មវិធីនេះបានប្រសាសន៍ដែលថា "សម្រាប់ប្រទេសកម្ពុជា នឹងគណ:កម្មាការណ៍អន្តរភូមិភាគ ព្រមទាំងសមាគមន៍ព្រះគម្ពីរ បានរៀបចំ អោយមានសិក្ខាសាលាទាំងបីភូមិភាគនេះឡើង គឺមានគោលបំណង ផ្តល់ឱកាសមួយ នឹងមេរៀនមួយ ដើម្បីជាបទពិសោធន៍មួយ ក្នុងការផ្តល់ដល់បងប្អូនដែលបានជម្រុចទឹកហើយ ជាពិសេសដល់បងប្អូន ដែលជាពន្លកថ្មី ដូចជាគេទទួលបានឱកាសមួយទៀត បានយល់ស្គាល់អំពីព្រះគម្ពីរ និងព្រះបន្ទូលនៅពេល ដែលគេបានអានផ្ទាល់ខ្លួន"។ លោកបានបន្តទៀតថា "នេះក៏ជាមធ្យោបាយមួយ បន្ទាប់ពីការរៀនអប់រំជំនឿ ក្នុងរយៈពេលយូររបស់ពួកគេ ដោយមានព្រះគម្ពីរជាអ្នកផ្តល់ នូវចំណេះដឹងបន្ថែមទៀត"។ នៅក្នុងកម្មវិធីនៃសិក្ខាសាលានេះ កញ្ញា រួម ខាន់ដា អាយុ ១៨ឆ្នាំ មកពីមណ្ឌល ដុនបូស្កូជ្រៃកោង បានមានចំណាប់អារម្មណ៍ និងមានប្រសាសន៍ដែលថា "ខ្ញុំមានការចាប់អារម្មណ៍ជាខ្លាំង ចំពោះការចូលរួមរបស់នាងខ្ញុំផ្ទាល់ ហើយក៏ជាលើកទីមួយផងដែរសម្រាប់នាងខ្ញុំ។ នៅក្នុងរយៈពេលបីថ្ងៃនេះ ខ្ញុំបានទទួលនូវបទពិសោធន៍យ៉ាងច្រើនដូចជា ការស្វែងយល់ពីព្រះគម្ពីរ ការស្តាប់ព្រះបន្ទូល និងការចែករំលែកនូវបទពិសោធន៍ចំណេះដឹងផ្សេងៗ អំពីជិវិតខ្លួនឯង និងព្រះគម្ពីរ"។ ស្របពេលនោះដែលលោក វាសនា អាយុ ២២ឆ្នាំ មកពីព្រះសហគមន៍ សៀមរាប បានប្រាប់ដល់រតន:យើងដែលថា "សម្រាប់ខ្ញុំផ្ទាល់ ចំពោះសិក្ខាសាលានេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់យើង ដែលជាគ្រីស្តបរិស័ទ ហើយកម្មវិធីនេះ បានផ្តល់ចំណេះដឹងជាច្រើនដល់រូបខ្ញុំទៀតផង"។ ចុងបញ្ចប់នៃសិក្ខាសាលាព្រះគម្ពីរ ក៏មានការចូលរួមពីសំណាក់លោកអភិបាល គីគេ នៅក្នុងពិធីអភិបូជា ក្នុងការចែកព្រះគម្ពីរ និងសញ្ញាប័ត្រដល់អ្នក ដែលបានចូលរួមផងដែរ។




Photo: An RittyRath

កាលពីថ្ងៃទី ២៣–២៥ ខែ តុលា ឆ្នាំ ២០១២ មានការប្រជុំ ប៉ាស្ទ័រាល់លើកទី ១៣ របស់ព្រះសហគមន៍ កាតូលិកបាត់ដំបង។ ការប្រជុំនេះធ្វើឡើងក្នុងគោលបំណង ចង់អោយអ្នកដឹកនាំព្រះសហគមន៍ នីមួយៗអនុវត្តន៍ នូវផែនការយុទ្ធសាស្ត្រ ។ ហើយគោលបំណងមួយទៀត គឺចង់ពង្រឹងជំនឿអ្នកដឹកនាំ រីគ្រីស្តបរិស័ទ អោយកាន់ជំនឿកាន់តែរឹងមាំ ដើម្បីបម្រើព្រះសហគមន៍។



Photo: Moy Samet

កាលពីល្ងាចថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ នៅព្រះសហគមន៍ កាតូលិកបាត់ដំបង បានរៀបចំពិធីប្រារព្ធព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទ នរោត្តម សីហនុ។

ពិធីនេះធ្វើឡើងស្របពេលពិធីអភិបូជា ដែលមានការចូលរួមពីសំណាក់លោកអភិបាល គីគេ និងលោកបូជាចារ្យ ប្រាំមួយអង្គ ព្រមទាំងបងប្អូនគ្រីស្តបរិស័ទចូលរួម រំលែកព្រះមរណៈទុក្ខ យ៉ាងក្រៀមក្រំរបស់ សម្តេចតាផងដែរ។

ក្នុងនោះផងដែរ មានការដុតធូបនៅមុខព្រះឆាយាល័ក្ខ ដើម្បីធ្វើការអធិដ្ឋាន ទូលព្រះជាម្ចាស់ទទួលវិញ្ញាណក្ខន្ធ របស់ព្រះអង្គ។

# អបអរសាទរពិធីបុណ្យភ្ជុំ

ដោយ:មុយ សាម៉េត



Photo: An RittyRath

បន្ទាប់ពីការកាន់វេនអស់រយះពេល ១៤ថ្ងៃ របស់បងប្អូនគ្រីស្តបរិស័ទរួចមក ពិធីបុណ្យភ្ជុំក៏ចូលមកដល់កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ នៅវេលាម៉ោង១០ នាទីព្រឹកនៅព្រះសហគមន៍ កាតូលិកបា–ត់ដំបង។ ពិធីបុណ្យនេះធ្វើឡើងជារៀងរាល់ឆ្នាំ និងមានជំនឿ តាំងពីចាស់ៗមកម្ល៉េះ។ ពិធីបុណ្យភ្ជុំធ្វើឡើងក្នុងគោលបំណង ដើម្បីថ្វាយអភិបូជារួមជាមួយនឹងការអធិដ្ឋាន ជូនចំពោះសន្តបុគ្គលទាំងឡាយ ដែលបានចែកឋានទៅ។ ក្នុងពិធីបុណ្យនេះ មានការចូលរួមពីលោកបូជាចារ្យ តូតេត នឹងបងប្អូនជាគ្រីស្តបរិស័ទយ៉ាងច្រើន ដែលបងប្អូនខ្លះមកពីទីឆ្ងាយទៀតផងក្នុងការមកចូលរួម នឹងសាច់ញាតិនៅក្នុងឱកាសនៃពិធីអភិបូជា សម្រាប់អបអរសាទរនៃពិធីបុណ្យភ្ជុំ។ ស្របពេលបងប្អូនគ្រីស្តបរិស័ទបានមកចូលរួម នៃពិធីអភិបូជានៃបុណ្យភ្ជុំនេះ ពួកគាត់បានយកនំចំណីអាហារ ផ្លែឈើ និងភេសជ្ជះគ្រប់មុខ ដើម្បីយកមកអោយលោកបូជាចារ្យ ធ្វើពិធីប្រសិទ្ធិពរនៅក្នុងពេលអភិបូជា។ ក្នុងនោះ បន្ទាប់ពីលោកបូជាចារ្យ តូតេត បានថ្វាយអភិបូជារួចមក លោកបូជាចារ្យក៏មានប្រសាសន៍ទាក់ទងនឹងពិធីបុណ្យភ្ជុំ ដែលថា "សម្រាប់យើងជាគ្រីស្តបរិស័ទបុណ្យភ្ជុំគឺជាបុណ្យរបស់យើងនៅក្នុង សាសនាគ្រីស្តហើយក៏ជាបុណ្យ ដែលយើងជួបជុំគ្នាជាមហាគ្រួសារតែមួយហើយមហាគ្រួសារក៏មានអត្ថន័យថា យើងមានសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយមានសហភាពហើយសហភាពនេះ គឺជាសហភាពរវាងជនដែលស្លាប់ទៅហើយ ហើយនឹងអ្នកដែលកំពុងរស់នៅនឹងមានជំនឿ ទៅលើព្រះជាម្ចាស់ទាំងបងប្អូនទាំងអស់ ដែលជាមនុស្សសុចរិត"។ នាពេលចុងបញ្ចប់នៃពីធីបុណ្យភ្ជុំ បងប្អូនបានទទួលទានអាហាររួមគ្នាយ៉ាងសប្បាយរីករាយ នៃការជួបជុំគ្នានេះ។

Photo: An Rittyrath



ក្រុមគ្រូអប់រំជំនឿនៅព្រះសហគមន៍ កាតូលិកបាត់ដំបង បានធ្វើពិធីសច្ចារ នៅពេលថ្វាយអភិបូជា ថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១២ កន្លងទៅថ្មីៗនេះ។ ក្នុងឆ្នាំសិក្សា ២០១២–២០១៣ នេះមានគ្រូចំនួន ១៣នាក់ និងបងស្រីចំនួន ២នាក់ ព្រមទាំងមានបងស្រី លក្ខណា ជាអ្នកសម្របសម្រួលក្នុងកម្មវិធីអប់រំជំនឿ និងលោកបូជាចារ្យ តូតេត ជាបូជាចារ្យគ្រប់គ្រង ក្នុងកម្មវិធីនេះផងដែរ។ ពិធីសច្ចាររបស់គ្រូអប់រំជំនឿនេះជាលើកទី៣ហើយ ដើម្បីបំរើព្រះសហគមន៍ដោយចែងរំលេកនូវជំនឿដល់ក្មេងៗ ជំនាន់ក្រោយ។

# ការប្រគល់សញ្ញាប័ត្រដល់សិស្សតន្ត្រី សម័យបញ្ចប់ការសិក្សាវគ្គ២




Photo: An Rittyrath

កាលពីល្ងាចថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១២ មានកម្មវិធីប្រគុំតន្ត្រីរបស់សិស្ស PMP ដែលបញ្ចប់ការសិក្សាផ្នែកតន្ត្រីសម័យវគ្គ២ នៅព្រះសហគមន៍ កាតូលិកបាត់ដំបង។ គោលបំណងនៃកម្មវិធីនេះ គឺធ្វើឡើងដើម្បីអោយសិស្សទាំងអស់ បានបញ្ចេញសមត្ថភាពរបស់ខ្លួន និងទេពកោសល្យ ដែលសិស្សទាំងអស់បានសិក្សារយះពេលយូរ ក្នុងការយកមកបង្ហាញដល់ទស្សនិកជនដែលបានអញ្ជើញចូលរួមនៅក្នុងកម្មវិធីនេះ។ ហើយម្យ៉ាងវិញទៀត ដើម្បីអោយពួកគេមានចិត្តក្លាហាន និងពង្រឹងសមត្ថភាពផ្ទាល់ខ្លួន ក្នុងការលេងតន្ត្រីជាមួយនឹងឧបករណ៍។ នៅក្នុងកម្មវិធីនេះផងដែរ ក៏មានការចូលរួមពីសំណាក់បងប្រុស សូ យើង ដែលជាអ្នកសម្របសម្រួលក្នុងកម្មវិធីបង្រៀនភ្លេងពេទ្យយាយជី ក្នុងការចែកនូវសញ្ញាប័ត្រ ដល់សិស្សទាំងអស់ដោយការបញ្ជាក់ពីការសិក្សារបស់ពួកគេអស់រយះពេលបីខែ។ ការប្រគុំតន្ត្រីរបស់សិស្ស PMP នេះក៏មានបីក្រុមផងដែរ ប៉ុន្តែសម្រាប់មួយក្រុមទៀតគឺជាសិស្សចាស់ និងពីរក្រុមទៀតជាសិស្សថ្មី។ ស្របពេលនោះដែលបងប្រុស សូ យើង ក៏មានចំណាប់អារម្មណ៍ថា "នៅក្នុងថ្ងៃនេះខ្ញុំមានអារម្មណ៍រីករាយមែនទេន ដែលបានឃើញពួកគាត់លេងបានល្អយ៉ាងនេះ ទោះជាមិនល្អមួយរយភាគរយ ក៏ប៉ុន្តែពួកគាត់ខិតខំប្រឹងប្រែងអស់ពីសមត្ថភាព"។ សូមបញ្ជាក់ថា សម្រាប់ការប្រគុំតន្ត្រីនេះ គឺជាលើកទីពីរហើយ ហើយក៏ទទួលការគាំទ្រពីសំណាក់បងប្អូន ដែលបានចូលមកទស្សនាផងដែរ។ សម្រាប់សិស្ស និងបងប្អូន ដែលចូលរួមយ៉ាងច្រើនកុះករនេះ ពិតជាមានភាពសប្បាយរីករាយជាមួយការប្រគុំតន្ត្រីរបស់ PMP។ **ដោយ:មុយ សាម៉េត**